Key Reply 2007

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាក្រុងភ្នំពេញ**

**លេខ:** ៣៧៤ ភត

ភ្នំពេញ ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ២០០៧

**ជំរាបមក**

**លោកប្រធានអង្គការ-សមាគមខ្មែរកម្ពុជាក្រោម** ✓

**<u>កម្មវត្ថុ</u>:** ករណីសំណើសុំធ្វើធម្មយាត្រាទៅកាន់ភ្នំឧត្តុង្គ នៅថ្ងៃទី ០៧-០៧-២០០៧ ។

**<u>យោង</u> :** -លិខិត ចុះថ្ងៃទី ២៧-០៦-២០០៧ របស់អង្គការ-សមាគមខ្មែរកម្ពុជាក្រោម ។

-ចំណាររបស់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចុះថ្ងៃទី ៥-៧-២០០៧ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកប្រធានជ្រាបថា : ចំពោះសំណើសុំធ្វើធម្មយាត្រាទៅកាន់ភ្នំឧត្តុង្គ នៅថ្ងៃទី ០៧-០៧-២០០៧ វេលាម៉ោង ០៦.០០ នាទី ដោយជួបជុំគ្នានៅរម្មណីយដ្ឋានវត្តភ្នំ ដែលមានព្រះសង្ឃ និងពុទ្ធបរិស័ទចូលរួម ១.០០០ នាក់ ដើម្បីធ្វើពិធីបួងសួងសុំសុខសន្តិភាពដល់ប្រជារាស្ត្រ និងព្រះសង្ឃខ្មែរដែលកំពុងរស់នៅលើទឹកដីកម្ពុជាក្រោមនោះ សាលាក្រុងភ្នំពេញមិនអាចអនុញ្ញាតជូនបានទេ ដោយហេតុថា ការស្នើសុំធ្វើធម្មយាត្រានេះផ្ទុយនឹងមាត្រា ២ នៃសង្ឃប្រកាសលេខ ៤០៣/០៧ ស.ជ.ក.ជ. ចុះថ្ងៃទី ០៨-០៦-២០០៧ ដែលមិនអនុញ្ញាតឱ្យព្រះសង្ឃចូលរួមធ្វើ បាតុកម្ម កូដកម្ម កុបកម្ម និងយករូបភាពធម្មយាត្រា ដើម្បីដង្ហែជាក្បួននានាធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈក្នុងសង្គម និងម្យ៉ាងវិញទៀត នៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៧ នេះអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ជាប់រវល់ការពារថ្នាក់ដឹកនាំកំពូលៗរបស់ប្រទេសចូលរួមក្នុងពិធីសម្ពោធរដ្ឋសភាជាតិថ្មី ។

អាស្រ័យហេតុនេះសូមលោកប្រធានជ្រាប និងអនុវត្តតាមខ្លឹមសារខាងលើ ។

**<u>ចំលងជូន</u>:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
" ដើម្បីជូនជ្រាប "
-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
-បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
-សាលាខណ្ឌដូនពេញ-ឫស្សីកែវ
-មន្ទីរធម្មការ និងសាសនារាជធានីភ្នំពេញ
" ដើម្បីមុខការ "
-ឯកសារ-កាលប្បវត្តិ

**ជ.អភិបាលសាលាក្រុងភ្នំពេញ**
**អភិបាលរង**

**មិរ៉ សារិន**

មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : ៧២២០៥៥ / ៧២៤១២៦ / ៧២៥៦២៥ / ៧២២៥៣១